State of California-Health and Human Services Agency
Department of Health Care Services
P.O. Box 989009, West Sacramento, CA 95798-9850

ព័ត៌មានសំខាន់សម្រាប់អ្នកមានពិការភាព និងអ្នកចាស់ជរា

មុនពេលលោកអ្នកបានចុះឈ្មោះក្នុងគម្រោងសុខភាព តើលោកអ្នកបានកំពុងជួបជួបគ្រូពេទ្យ Medi-Cal ណាម្នាក់ ដែរឬទេ ?
លោកអ្នកប្រហែលអាចជួបគ្រូពេទ្យនោះជាបន្តទៀតបាន ជារយៈពេលដល់ទៅ 12 ខែ នៅពេលអ្នកកំពុងចូលរួមក្នុងគម្រោងសុខភាព បើសិនជាគ្រូពេទ្យនោះយល់ព្រមធ្វើការជាមួយគម្រោងសុខភាព។ ប្រសិនបើលោកអ្នកនៅតែចង់ជួបគ្រូពេទ្យនោះ សូមធ្វើតាមជំហានទាំងឡាយខាងក្រោមនេះ៖

- ទូរស័ព្ទទៅគម្រោងសុខភាពថ្មីរបស់លោកអ្នក — សូមមើលទំព័របន្ទាប់ទៀត សម្រាប់លេខទូរស័ព្ទរបស់គម្រោងសុខភាពលោកអ្នក
- ប្រាប់គម្រោងសុខភាពរបស់លោកអ្នក ថាលោកអ្នកនៅតែចង់ជួបគ្រូពេទ្យ Medi-Cal របស់លោកអ្នកជាបន្តទៀត
- ប្រាប់ដល់គម្រោងសុខភាពរបស់លោកអ្នក នូវឈ្មោះនៃគ្រូពេទ្យ Medi-Cal របស់លោកអ្នក
- គម្រោងសុខភាពត្រូវតែទាក់ទងទៅគ្រូពេទ្យនោះជំនួសលោកអ្នក ហើយប្រាប់លោកអ្នកថា តើលោកអ្នកអាចជួបគ្រូពេទ្យនោះជាបន្តទៀតបាន ឬមិនបានទេ
- ប្រសិនបើគម្រោងសុខភាពឆ្លើយថា មិនបានទេ សូមឲ្យគេប្រាប់លោកអ្នកពីរបៀបដើម្បីដាក់ពាក្យតវ៉ា

គម្រោងសុខភាពរបស់លោកអ្នកអាចជួយលោកអ្នកដើម្បីទទួល៖

- ជំនួយក្នុងការរកមធ្យោបាយដឹកជញ្ជូនទៅកាន់ការិយាល័យរបស់គ្រូពេទ្យ ហើយនិងទៅផ្ទះវិញ
- ព័ត៌មានជាទ្រង់ទ្រាយផ្សេងទៀត រួមទាំងអក្សរ Braille, សំឡេងស្តាប់, ហើយនិងអក្សរធំៗ
- ជំនួយដើម្បីឆ្លើយសំនួររបស់លោកអ្នក ដោយភាសាផ្ទាល់របស់លោកអ្នក រួមទាំងភាសា American Sign Language ដែរ

លោកអ្នកអាចជ្រើសរើសគ្រូពេទ្យម្នាក់ ដែលបំពេញសេចក្តីត្រូវការខាងពិការភាពរបស់លោកអ្នក។
ទូរស័ព្ទទៅគម្រោងសុខភាព ដើម្បីសួរព័ត៌មានអំពីអ្នកផ្តល់សេវាកម្ម ដែលបំពេញសេចក្តីត្រូវការពិការភាពរបស់លោកអ្នក រួមទាំង៖

- កន្លែងចតឡានសម្រាប់អ្នកពិការ
- ផ្លូវជម្រាលឡើងពីចិញ្ចើមថ្នល់ ឬផ្លូវជម្រាលផ្សេងទៀត
- ទ្វារដែលបើកធំល្មមសម្រាប់កៅអីកង់ ឬកៅអីយន្ត
- បន្ទប់ពិនិត្យដែលអ្នកពិការអាចចូលបាន
- តុពិនិត្យ និងជញ្ជីងថ្លឹងដែលអ្នកពិការអាចឡើងបាន

បញ្ជីឈ្មោះអ្នកផ្តល់សេវាកម្មរបស់គម្រោងសុខភាពលោកអ្នក ប្រហែលអាចមានសញ្ញា ដើម្បីធ្វើឲ្យលោកអ្នកងាយស្រួល ក្នុងការជ្រើសរើសអ្នកផ្តល់សេវាកម្ម ដែលមានជម្រើសដូចក្នុងបញ្ជីខាងលើនេះ។ ឆែកមើលបញ្ជីអ្នកផ្តល់សេវាកម្មរបស់គម្រោងសុខភាពលោកអ្នក រកបញ្ជីសញ្ញា និងអត្ថន័យរបស់សញ្ញានីមួយៗ។

ដើម្បីទូរស័ព្ទទៅគម្រោងរបស់លោកអ្នក សូមប្រើលេខទូរស័ព្ទដូចខាងក្រោមនេះ៖

ឈ្មោះគម្រោង	លេខទូរស័ព្ទ	TDD/TTY
Health Plan Name	(XXX) XXX-XXXX	(XXX) XXX-XXXX

ប្រសិនបើលោកអ្នកនៅតែត្រូវការជំនួយ សូមទូរស័ព្ទទៅកាន់ការិយាល័យរបស់មន្ត្រីទទួលបណ្តឹងតាំ Medi-Cal តាមលេខទូរស័ព្ទ (888) 452-8609 ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច។ ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ។

បើគម្រោងរបស់លោកអ្នកបដិសេធ បន្ថយ ឬបញ្ឈប់សេវាកម្ម លោកអ្នកអាចដាក់ពាក្យតាំ ជាមួយនឹងគម្រោងសុខភាពរបស់លោកអ្នកបាន។ បើលោកអ្នកមិនទទួលដំណោះស្រាយទេ លោកអ្នកមានសិទ្ធិទទួល State Hearing [រដ្ឋសវនាការ] មួយដែរ។ លោកអ្នកអាចដាក់ពាក្យសុំ State Hearing ដោយទូរស័ព្ទទៅលេខ (800) 952-5253 ឬ TDD/TTY (800) 952-8349 ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច។ ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ។